# ប្រភេទនៃបណ្តឹង នីតិវិធី និង ការសម្រេចសេចក្តីនៃបណ្តឹងនីមួយៗ

ក្រសួងយុត្តិធម៌ វិទ្យាស្ថានស្រាវជ្រាវទូទៅអំពីកិច្ចការច្បាប់
នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ
សាស្ត្រាចារ្យ Fukuoka Fumie

# ទ្រឹស្តីទូទៅ (1: បណ្តឹងទាមទារឲ្យផ្តល់តាវកាលិក)

- តើបណ្តឹងទាមទារឲ្យផ្តល់តាវកាលិកជាអ្វី?
  គឺជាបណ្តឹងដែលទាមទារឲ្យតុលាការចេញសាលក្រមបង្គាប់ឲ្យចុងចម្លើយផ្តល់តាវកាលិកដែលបានកំណត់   ដោយផ្អែកលើការអះអាងអំពីអត្ថិភាពនៃសិទ្ធិទាមទារឲ្យផ្តល់តាវកាលិកតាមច្បាប់សារធាតុដែលបានកំណត់ តាមរយៈការទាមទារតាមផ្លូវបណ្តឹង។

ឧទា៖ បណ្តឹងទាមទារប្រាក់ថ្លៃលក់ទិញ បណ្តឹងទាមទារឲ្យសងប្រាក់កម្ចី
បណ្តឹងទាមទារនូវការចុះបញ្ជីផ្ទេរ

# ទ្រឹស្តីទូទៅ (1: បណ្តឹងទាមទារឲ្យផ្តល់តាវកាលិក)

- អានុភាពនៃសាលក្រម ឬ សាលដីកាបង្គាប់ឲ្យផ្តល់តាវកាលិក

  អាជ្ញាអស់ជំនុំដែលមានលក្ខណៈសារធាតុ ៖ អានុភាពដែលធ្វើឲ្យអត្ថិភាពនៃសិទ្ធិទាមទារឲ្យផ្តល់តាវកាលិករបស់ដើមចោទចូលជាស្ថាពរ។

  អានុភាពអនុវត្ត៖ អានុភាពដែលដើមចោទអាចធ្វើឲ្យសម្រេចនូវសិទ្ធិទាមទារ ដែលត្រូវបានទទួលស្គាល់ដោយសាលក្រម ឬ សាលដីកា តាមរយៈការអនុវត្តដោយបង្ខំ ផ្អែកតាមសាលក្រម ឬ សាលដីកានោះ។

  ※លិខិតដែលត្រូវបានទទួលស្គាល់អំពីអានុភាពអនុវត្ត គេហៅថា លិខិតអនុវត្ត (យោងមាត្រា350 កថាខណ្ឌទី1)

# ទ្រឹស្តីទូទៅ (1: បណ្តឹងទាមទារឲ្យផ្តល់តាវកាលិក)

> **សាលក្រមបញ្ជាក់មិនក្លាយជាលិខិតអនុវត្តទេ**
> ↓
> **មិនអាចអនុវត្តដោយបង្ខំទេ**

ក្រមនីតិវិធីរដ្ឋប្បវេណីមាត្រា 350 (លិខិតអនុវត្ត)

1 ការអនុវត្តដោយបង្ខំត្រូវធ្វើឡើយ ដោយផ្អែកលើលិខិតអនុវត្ត។

2 លិខិតអនុវត្ត គឺជាលិខិតដែលបានកំណត់ដូចខាងក្រោម៖

(1) សាលក្រម ឬ សាលដីកាបង្គាប់ឲ្យផ្តល់តាវកាលិកដែលបានចូលជាស្ថាពរ

(2) សាលក្រម ឬ សាលដីកាបង្គាប់ឲ្យផ្តល់តាវកាលិកដែលភ្ជាប់ជាមួយនឹងការប្រកាសឲ្យអនុវត្តជាបណ្តោះអាសន្ន។

(3) ដីកាសម្រេចបង្គាប់ឲ្យផ្តល់តាវកាលិក។ ប៉ុន្តែ ចំពោះដីកាសម្រេចដែលមិនត្រូវមានអានុភាព បើមិនទាន់ចូលជាស្ថាពរវិញ មានកម្រិតតែដីកាសម្រេចនោះបានចូលជាស្ថាពរហើយ។

<សង្ខេប>

(9) កំណត់ហេតុដែលបានកំណត់នៅក្នុងមាត្រា 222 (អានុភាពនៃកំណត់ហេតុស្តីពីការសះជាជាអាទិ៍) នៃក្រមនេះ និង កំណត់ហេតុផ្សេងទៀតដែលមានអានុភាពដូចសាលក្រម ឬ សាលដីកាដែលបានចូលជាស្ថាពរ។

# ទ្រឹស្ដីទូទៅ (1: បណ្ដឹងទាមទារឲ្យផ្ដល់តាវកាលិក)

ដើម្បីអនុវត្តសាលក្រម ឬ សាលដីកាបង្គាប់ឲ្យផ្ដល់តាវកាលិក ចាំបាច់ត្រូវមានរូបមន្តអនុវត្ត លើកលែងតែករណីលើកលែងមួយផ្នែក (ក្រមនីតិវិធីរដ្ឋប្បវេណីមាត្រា 354 កថាខណ្ឌទី1)។

→ តើករណីលើកលែងមួយផ្នែកជាអ្វី?

សាលក្រម ឬ សាលដីកានៃបណ្ដឹងរឿងក្ដីដែលមានចំនួនទឹកប្រាក់តិច និង ដីកាសម្រេចដាស់តឿន

(ដោយសារតែគោលបំណងនៃសាលក្រមខាងលើនេះ ធ្វើឡើងដើម្បីទទួលបានលិខិតអនុវត្តក្នុងរយៈពេលដ៏ឆាប់រហ័សតាមរយៈនីតិវិធីងាយស្រួល ដូចនេះហើយមិនត្រូវការរូបមន្តអនុវត្តទេ នៅពេលដែលយកភាគីដែលបានកំណត់នៅក្នុងលិខិតអនុវត្តនោះ ធ្វើជាម្ចាស់បំណុលនៃការអនុវត្ត និង កូនបំណុលនៃការអនុវត្ត)

# ទ្រឹស្តីទូទៅ (1: បណ្តឹងទាមទារឲ្យផ្តល់តាវកាលិក)

- សេចក្តីសម្រេចបញ្ចប់នៃបណ្តឹងទាមទារឲ្យផ្តល់តាវកាលិក
  "បង្គាប់ឲ្យចុងចម្លើយបង់ប្រាក់ចំនួន....... ឲ្យទៅដើមចោទ។"
  "បង្គាប់ឲ្យចុងចម្លើយធ្វើនីតិវិធីចុះបញ្ជីផ្ទេរកម្មសិទ្ធិទាំងស្រុងនូវដីដែលមានសរសេរក្នុងតារាងឧបសម្ព័ន្ធនៃបញ្ជីសារពើភ័ណ្ឌស្តីពីសិទ្ធិប្រត្យក្ស ដោយមូលហេតុការលក់ទិញថ្ងៃទី.....ខែ.....ឆ្នាំ.....។"

※ត្រូវចង្អុលបង្ហាញនូវត្រួសៗ ដើម្បីឲ្យអាចដឹងអត្ថន័យច្បាស់លាស់ដោយគ្រាន់តែមើលមួយភ្លែត ។
※ប្រើប្រាស់សំនួន និង ឃ្លាឃោងដែលមានភាពអរូបិយ ហើយដោយមិនបញ្ចូលនូវលក្ខណៈគតិយុត្តនៃការផ្តល់តាវកាលិក ឬ ការភ្ជាប់មូលហេតុនៃតាវកាលិកទេ។

# ប្រភេទបណ្តឹង (2:បណ្តឹងទាមទារឲ្យបញ្ជាក់)

- តើបណ្តឹងទាមទារឲ្យបញ្ជាក់ជាអ្វី?
  គឺជាបណ្តឹងទាមទារឲ្យតុលាការចេញសាលក្រមបញ្ជាក់អំពីអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្ត ដោយផ្អែកលើការអះអាងរបស់ដើមចោទអំពី អត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលបានកំណត់ ដោយធ្វើការទាមទារតាមរយៈតាមផ្លូវបណ្តឹង។

  ឧទា៖ បណ្តឹងទាមទារឲ្យបញ្ជាក់នត្ថិភាពនៃកាតព្វកិច្ច
  បណ្តឹងទាមទារឲ្យបញ្ជាក់អំពីកម្មសិទ្ធិ

# ទ្រឹស្តីទូទៅ( 2:បណ្តឹងទាមទារឲ្យបញ្ជាក់ )

- ផលប្រយោជន៍នៃបណ្តឹងទាមទារឲ្យបញ្ជាក់

  កម្មវត្ថុនៃការទាមទារឲ្យបញ្ជាក់មានមានច្រើនប្រភេទដែលមិនអាចកំណត់បានទេ។ ដើម្បីជៀសវាងការបន្តនីតិវិធីនៃបណ្តឹងដោយមិនមានភាពចាំបាច់ គេបានកំណត់យកតែបណ្តឹងដែលមានលក្ខណៈចាំបាច់ ដើម្បីដោះស្រាយវិវាទជាក់ស្តែង។

①ភាពត្រឹមត្រូវនៃមធ្យោបាយក្នុងការប្រើប្រាស់បណ្តឹងទាមទារឲ្យបញ្ជាក់ (គោលការណ៍នៃប្រព័ន្ធបន្ថែម)

②ភាពត្រឹមត្រូវនៃកម្មវត្ថុក្នុងការទាមទារឲ្យបញ្ជាក់

③ផលប្រយោជន៍នៃការទាមទារឲ្យបញ្ជាក់ភ្លាមៗ

# ទ្រឹស្តីទូទៅ( 2:បណ្តឹងទាមទារឲ្យបញ្ជាក់ )

①ភាពត្រឹមត្រូវនៃមធ្យោបាយក្នុងការប្រើប្រាស់បណ្តឹងទាមទារឲ្យបញ្ជាក់ (គោលការណ៍នៃប្រព័ន្ធបន្ថែម)

ឧទា៖ A ទាមទារឲ្យ B សងប្រាក់ចំនួន 200 ដុល្លារ ប៉ុន្តែ B អះអាងថា បានសងប្រាក់ចំនួន 100 ដុល្លារហើយ។ ក្នុងករណីនេះ តើ A ត្រូវដាក់ពាក្យបណ្តឹងប្រភេទណា?

○បណ្តឹងទាមទារឲ្យសងប្រាក់កម្ចី

នៅពេលដែលសាលក្រមបានទទួលស្គាល់ការទាមទារ បានចូលជាស្ថាពរ សាលក្រមនោះនឹងមានអាជ្ញាអស់ជំនុំជាលក្ខណៈសារធាតុ និង មានអានុភាពអនុវត្ត។

×បណ្តឹងទាមទារឲ្យបញ្ជាក់អំពីអត្ថិភាពនៃកាតព្វកិច្ច

ទោះបីជាសាលក្រមទទួលស្គាល់ការទាមទារបានចូលជាស្ថាពរក៏ដោយ ក៏សាលក្រមនោះគ្រាន់តែបញ្ឈប់នូវការកើតឡើងនៃអាជ្ញាអស់ជំនុំជាលក្ខណៈសារធាតុលើអត្ថិភាពនៃកាតព្វកិច្ចប៉ុណ្ណោះ។ បើសិនជា B មិនព្រមអនុវត្តដោយស្ម័គ្រចិត្តទេនោះ A ត្រូវតែដាក់ពាក្យបណ្តឹងទាមទារឲ្យផ្តល់តាវកាលិកដើម្បីអាចទទួលបានលិខិតអនុវត្ត ដូច្នេះ ធ្វើឲ្យចំណាយពេលវែងឆ្ងាយ។

# ទ្រឹស្តីទូទៅ( 2:បណ្តឹងទាមទារឲ្យបញ្ជាក់ )

②ភាពត្រឹមត្រូវនៃកម្មវត្ថុក្នុងការទាមទារឲ្យបញ្ជាក់

ជាគោលការណ៍ កម្មវត្ថុនៃការទាមទារឲ្យបញ្ជាក់ គឺជាទំនាក់ទំនងនៃសិទ្ធិ ឬ ឋានៈតាមផ្លូវច្បាប់នាពេលបច្ចុប្បន្ន។

i បើសិនជាបញ្ជាក់អំពីទំនាក់ទំនងនៃសិទ្ធិ ឬ ឋានៈតាមផ្លូវច្បាប់ក្នុងពេលអតីតកាលក៏ដោយ ក៏ភាគច្រើនសិទ្ធិ ឬ ឋានៈនោះនៅក្នុងពេលបច្ចុប្បន្នមានការផ្លាស់ប្តូរ ហើយមិនមានប្រយោជន៍ក្នុងការដោះស្រាយវិវាទនាពេលបច្ចុប្បន្នទេ។

ii ដើម្បីធ្វើការបញ្ជាក់អំពីទំនាក់ទំនងនៃសិទ្ធិ និង ឋានៈតាមផ្លូវច្បាប់នាពេលអនាគត តុលាការត្រូវធ្វើការសេចក្តីសម្រេចដោយផ្អែកលើការព្យាករណ៍ទុក ហើយក្នុងករណីដែលលទ្ធផលខុសពីការព្យាករណ៍ទុក នឹងធ្វើឲ្យសាលក្រមនោះគ្មានន័យ ហើយមិនមានប្រយោជន៍អ្វីចំពោះការដោះស្រាយវិវាទទេ។

iii ទោះបីជាយកទំនាក់ទំនងនៃអង្គហេតុមកធ្វើជាកម្មវត្ថុនៃការបញ្ជាក់ក៏ដោយ ក៏ទំនាក់ទំនងនៃអង្គហេតុនេះមិនបានផ្សារភ្ជាប់ដោយផ្ទាល់ចំពោះការដោះស្រាយវិវាទតាមផ្លូវច្បាប់នាពេលបច្ចុប្បន្នដែរ។

# ទ្រឹស្តីទូទៅ( 2:បណ្តឹងទាមទារឲ្យបញ្ជាក់ )

- អំពី i
  ទោះបីជាការទទួលស្គាល់នូវទំនាក់ទំនងសិទ្ធិ និង ឋានៈតាមផ្លូវច្បាប់នាពេលអតីតកាលក៏ដោយ បើសិនជាការទទួលស្គាល់នោះនឹងក្លាយជាមូលដ្ឋាននៃទំនាក់ទំនងគតិយុត្តនាពេលបច្ចុប្បន្ន ឬ តាមរយៈការចូលជាស្ថាពរនៃសាលក្រមបញ្ជាក់អំពីទំនាក់ទំនងសិទ្ធិ អាចធ្វើឲ្យដោះស្រាយនូវជម្លោះទូទៅទាំងអស់ដែលបានកើតឡើងនោះ កម្មវត្ថុទាំងនេះ នឹងអាចទទួលស្គាល់ថាជាកម្មវត្ថុនៃការបញ្ជាក់បាន។

ឧទាហរណ៍នៃសំណុំរឿងនៅប្រទេសជប៉ុន៖

・បណ្តឹងទាមទារឲ្យបញ្ជាក់អំពីទំនាក់ទំនងរវាងឪពុកម្តាយ និង កូន ដែលឪពុកម្តាយបានប្តឹងក្រោយមរណៈភាពរបស់កូន（最大判S45.7.15民集24巻7号861頁）

ទំនាក់ទំនងរវាងឪពុកម្តាយ និង កូន គឺជាទំនាក់ទំនងគតិយុត្តដែលនឹងក្លាយជាមូលដ្ឋាននៃទំនាក់ទំនងអត្រានុកូដ្ឋានចំពោះអ្នកដែលនៅរស់ ហើយទំនាក់ទំនងនេះ តុលាការបានទទួលស្គាល់ថា មានភាពចាំបាច់ក្នុងការដោះស្រាយវិវាទគតិយុត្តនាពេលបច្ចុប្បន្នរបស់អ្នកនៅរស់ ដូច្នេះ ហើយសំណុំរឿងនេះ ប្រាកដជាមានផលប្រយោជន៍នៃការបញ្ជាក់។

・បណ្តឹងទាមទារឲ្យបញ្ជាក់អំពីមត៌ក（最判S61.3.13民集40巻2号389頁)

ដោយសារតែស្ថានភាពនៅពេលនោះបានបង្ហាញថា ទ្រព្យសម្បត្តិដែលនឹងត្រូវក្លាយជាកម្មវត្ថុនៃមត៌ក គឺជាមត៌កដែលស្ថិតនៅក្រោមកម្មសិទ្ធិអវិភាគរបស់សន្តតិជនមុនការបែងចែក ដូចនេះ តុលាការបានទទួលស្គាល់ថា កម្មវត្ថុនៃការបញ្ជាក់នេះ មានភាពត្រឹមត្រូវជាកម្មវត្ថុក្នុងការបញ្ជាក់ អំពីទំនាក់ទំនងគតិយុត្តក្នុងពេលបច្ចុប្បន្ន។

# ទ្រឹស្តីទូទៅ( 2:បណ្តឹងទាមទារឲ្យបញ្ជាក់ )

- អំពីii

ទោះបីជាទំនាក់ទំនងនៃសិទ្ធិ និង ឋានៈតាមផ្លូវច្បាប់នាពេលអនាគត មិនអាចក្លាយជាកម្មវត្ថុការបញ្ជាក់ក៏ដោយ ប៉ុន្តែ បើមានករណីដែលទំនាក់ទំនងគតិយុត្តអាចធ្វើឲ្យមានការផ្លាស់ប្តូរនូវទំនាក់ទំនងសិទ្ធិ និង ឋានៈតាមផ្លូវច្បាប់នាពេលបច្ចុប្បន្នដែលបានភ្ជាប់លក្ខខណ្ឌនោះ គេនឹងទទួលស្គាល់ថាមានប្រយោជន៍ក្នុងបញ្ជាក់។

ឧទាហរណ៍នៃសំណុំរឿងនៅប្រទេសជប៉ុន៖

- បណ្តឹងទាមទារឲ្យបញ្ជាក់អំពីអត្ថិភាពនៃសិទ្ធិទាមទារឲ្យសងប្រាក់កក់ដែលបានធ្វើឡើងខណៈពេលដែលភតិសន្យាលើអាគារនោះកំពុងតែបន្ត（最判H11.1.21民集53巻1号1頁）

  សិទ្ធិទាមទារឲ្យសងប្រាក់កក់នេះ បានកំណត់នូវលក្ខខណ្ឌថា ជាសិទ្ធិដែលកើតឡើងរួមគ្នាជាមួយនឹងប្រាក់ដែលនៅសល់ ក្រោយពីបានកាត់សិទ្ធិលើបំណុលដែលត្រូវបានធានាដែលបានកើតឡើងប្រាក់កក់នោះ ហើយសិទ្ធិនេះមាននៅក្រោយពេលដែលបញ្ចប់ការជួល ហើយភាគីបានចុះចេញ និង ប្រគល់វត្ថុជួលនោះ។ ប៉ុន្តែ តុលាការបានសម្រេចថា វាជាសិទ្ធិក្នុងពេលបច្ចុប្បន្នដែលមានភ្ជាប់លក្ខខណ្ឌ ទោះបីជាការទាមទារឲ្យបញ្ជាក់នោះបានធ្វើឡើងនៅមុនពេលបញ្ចប់ភតិសន្យាក៏ដោយ។

# ភស្តុតាង(2:បណ្តឹងទាមទារឲ្យបញ្ជាក់)

- អំពីiii

  ជាគោលការណ៍ ការទាមទារឲ្យបញ្ជាក់អំពីអត្ថិភាព ឬ នត្ថិភាពនៃអង្គហេតុពុំត្រូវបានអនុញ្ញាតទេ។ ប៉ុន្តែ ករណីលើកលែង ដែលគេបានអនុញ្ញាតឲ្យធ្វើបណ្តឹងទាមទារឲ្យបញ្ជាក់អំពីភាពត្រឹមត្រូវ ឬ មិនត្រូវត្រូវនៃឯកសារដែលបញ្ជាក់នូវទំនាក់ទំនងគតិយុត្ត (យោង ក្រមនីតិវិធីរដ្ឋប្បវេណីមាត្រា155)។

# ទ្រឹស្តីទូទៅ( 2:បណ្តឹងទាមទារឲ្យបញ្ជាក់ )

※ គោលបំណងនៃបណ្តឹងគឺ ធ្វើការដោះស្រាយវិវាទដែលទាក់ទងនឹង អត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តជាក់ស្តែង ដើម្បីធ្វើការការពារសិទ្ធិរបស់គូភាគី។

ជាទូទៅ ជាបណ្តឹងដែលទាមទារឲ្យបញ្ជាក់អំពីអត្ថិភាព (នត្ថិភាព) នៃអានុភាពគតិយុត្ត

↓

មិនមានភាពត្រឹមត្រូវតាមច្បាប់

→ ចុះ បើសិនជាភាគីបានដាក់ពាក្យបណ្តឹងបែបនេះវិញ?

→ តុលាការអនុវត្តនូវសិទ្ធិឲ្យបំភ្លឺ (ក្រមនីតិវិធីរដ្ឋប្បវេណីមាត្រា90) ហើយធ្វើការបញ្ជាក់អំពីខ្លឹមសារដែលជាដើមចោទបានទាមទារជាអាទិ៍។ ក្រោយពីធ្វើបែបនេះ ហើយឃើញថា ការទាមទាររបស់ដើមចោទ មិនមែនជា ការទាមទារឲ្យបញ្ជាក់អំពីមោឃភាពតាមផ្លូវច្បាប់ទេ ហើយវាគឺជាការបញ្ជាក់អំពីនត្ថិភាពនៃករណីយកិច្ចរបស់ខ្លួនទៅវិញនោះ តុលាការនឹងជំរុញឲ្យដើមចោទធ្វើការផ្លាស់ប្តូរបណ្តឹង (ច្បាប់ដដែល មាត្រា84 កថាខណ្ឌទី1) មកជា ការទាមទារឲ្យបញ្ជាក់អំពីនត្ថិភាពនៃករណីយកិច្ចរបស់ខ្លួនវិញ (ដោយផ្អែកតាមច្បាប់នោះ) ។

# ទ្រឹស្តីទូទៅ( 2:បណ្តឹងទាមទារឲ្យបញ្ជាក់ )

③ផលប្រយោជន៍នៃការចូលជាស្ថាពរភ្លាម

ឋានៈតាមផ្លូវច្បាប់ ឬ សិទ្ធិ និង ផលប្រយោជន៍ជាក់ស្តែរបស់ដើមចោទ ដែលត្រូវបានបដិសេធដោយចុងចម្លើយ ហើយមានការកើតឡើងនូវអស្ថេរភាព និង គ្រោះថ្នាក់កើតចំពោះទំនាក់ទំនងសិទ្ធិ និង ឋានៈតាមផ្លូវច្បាប់របស់ដើមចោទនៅខណៈនោះ ដូច្នេះហើយ មានភាពចាំបាច់ដែលសាកសមក្នុងការដោះស្រាយវិវាទក្នុងកម្រិតភ្លាមៗ តាមរយៈបណ្តឹងទាមទារឲ្យបញ្ជាក់។

ឧទាៈក្នុងករណីដែលកូនស្រីច្បង B មានវិវាទតាមរយៈបណ្តឹងទាមទារឲ្យបញ្ជាក់អំពីសុពលភាពនៃការចាត់ចែងទ្រព្យរបស់ឪពុក A ក្នុងពេលដែល A នៅមានជីវិត ឋានៈដែលបានសន្មតថា ជាសន្តតិជនបែបនេះ មិនហួសពីសិទ្ធិនៃការរំពឹងទុកទេ ហើយមិនអាចនិយាយថា ជាគ្រោះថ្នាក់ចំពោះឋានៈតាមផ្លូវច្បាប់របស់ដើមចោទកំពុងកើតមានឡើងទេ។

# ទ្រឹស្តីទូទៅ( 2:បណ្តឹងទាមទារឲ្យបញ្ជាក់ )

- សេចក្តីសម្រេចបញ្ចប់នៃបណ្តឹងទាមទារឲ្យបញ្ជាក់

  "បញ្ជាក់អំពីនត្ថិភាពនៃកាតព្វកិច្ចឲ្យសងប្រាក់ចំនួន......យ៉េនពីដើមចោទទៅឲ្យចុងចម្លើយ ផ្អែកតាមកិច្ចសន្យាខ្ចីបរិភោគចុះថ្ងៃទី.....ខែ.....ឆ្នាំ.....រវាងដើមចោទ និងចុងចម្លើយ" ។

  "បញ្ជាក់ថាដើមចោទមានកម្មសិទ្ធិលើដីដែលសរសេរនៅក្នុងបញ្ជីសារពើភ័ណ្ឌស្តីពីសិទ្ធិប្រត្យក្ស។"

  ※ ពាក្យពេចន៍នៅក្នុងសេចក្តីសម្រេចបញ្ចប់ សរសេរថា "បញ្ជាក់......។" ។

  ※ គួរតែជៀងវាងនូវសរសេដែលធ្វើឲ្យយល់ច្រឡំថា ជាសាលក្រមដែលបង្គាប់ឲ្យផ្តល់តាវកាលិកជាអាទិ៍ ( ឧទា៖ ការសេសេរថា "បង្គាប់ឲ្យចុងចម្លើយបញ្ជាក់......ឲ្យទៅដើមចោទ។" ឬ "ចុងចម្លើយត្រូវតែបញ្ជាក់........។"

# ទ្រឹស្តីទូទៅ( 3:បណ្តឹងទាមទារឲ្យបង្កើត ប្តូរ ឬ រំលត់ទំនាក់ទំនងគតិយុត្ត )

- តើបណ្តឹងទាមទារឲ្យបង្កើត ប្តូរ ឬ រំលត់ទំនាក់ទំនងគតិយុត្តជាអ្វី?

  គឺជា បណ្តឹងដែលទាមទារឲ្យតុលាការចេញសាលក្រមប្រកាសអំពីការបង្កើតនូវទំនាក់ទំនងគតិយុត្ត (ការកើតមានឡើង ការប្តូរ ឬ ការរំលត់) ជាថ្មី ដោយផ្អែកលើការអះអាងអំពីអត្ថិភាពនៃសិទ្ធិក្នុងបង្កើត ប្តូរ ឬ រំលត់ទំនាក់ទំនងគតិយុត្ត ឬ ផ្អែកលើមូលហេតុនៃការបង្កើត ការប្តូរ ឬ ការរំលត់ទំនាក់ទំនងគតិយុត្តដែលបានកំណត់ តាមរយៈការទាមទារតាមផ្លូវបណ្តឹង។

  ឧទាហរណ៍៖ បណ្តឹងទាមទារឲ្យលែងលះ (ក្រមរដ្ឋប្បវេណីមាត្រា978)

  បណ្តឹងទាមទារឲ្យទទួលស្គាល់ (ច្បាប់ដដែល មាត្រា1001)

# ទ្រឹស្តីទូទៅ( 3:បណ្តឹងទាមទារឲ្យបង្កើត ប្តូរ ឬ រំលត់ទំនាក់ទំនងគតិយុត្ត )

- អានុភាពនៃបណ្តឹងទាមទារឲ្យបង្កើត ប្តូរ ឬ រំលត់ទំនាក់ទំនងគតិយុត្ត

ឧទា៖ ករណីបណ្តឹងទាមទារឲ្យទទួលស្គាល់ ។ នៅពេលដែលមានសាលក្រមស្តីអំពីការទទួលស្គាល់ដោយផ្អែកតាមបណ្តឹងនេះ នឹងមានការកើតឡើងនូវទំនាក់ទំនងជាដំបូងរវាងឪពុកម្តាយ និងកូន ហើយអានុភាពនៃសាលក្រមនោះនឹងកើតមានឡើងចំពោះគ្រប់ទំនាក់ទំនងដែលធ្វើឡើងជាមួយនឹងបុគ្គលដែលមានផលប្រយោជន៍ពាក់ព័ន្ធ (ច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល មាត្រា17 កថាខណ្ឌទី1) ។

# ទ្រឹស្តីទូទៅ(3:បណ្តឹងទាមទារឲ្យបង្កើត ប្តូរ ឬ រំលត់ទំនាក់ទំនងគតិយុត្ត)

- កម្មវត្ថុនៃបណ្តឹងទាមទារឲ្យបង្កើត ប្តូរ ឬ រំលត់គតិយុត្ត
  ត្រូវតែជាកម្មវត្ថុដែលធ្វើការអះអាងអំពីអត្ថិភាពនៃសិទ្ធិបង្កើត ប្តូរ ឬ រំលត់ទំនាក់ទំនងគតិយុត្តដែលបានកំណត់ (សិទ្ធិលែងលះ សិទ្ធិលុបចោលអាពាហ៍ពិពាហ៍ សិទ្ធិទាមទារឲ្យទទួលស្គាល់ជាដើម) ឬ អត្ថិភាពនៃមូលហេតុក្នុងការបង្កើត ប្តូរ ឬ ទំនាក់ទំនងគតិយុត្តដែលបានកំណត់ (មូលហេតុនៃការលុបចោលសេចក្តីសម្រេចរបស់មហាសន្និបាតម្ចាស់ភាគហ៊ុន មូលហេតុនៃការជំនុំជម្រះសាជាថ្មីទៅលើសាលក្រម ឬ សាលដីកាដែលបានចូលស្ថាពរ)ជាដើម។
  → ប្រសិនបើតុលាការពុំមានបទដ្ឋានតាមផ្លូវច្បាប់ណាមួយ ដើម្បីយកមកបង្កើត ប្តូរ ឬ រំលត់ទំនាក់ទំនងគតិយុត្តទេ បណ្តឹងនោះ មិនមែនជាបណ្តឹងទាមទារឲ្យបង្កើត ប្តូរ ឬ រំលត់ទំនាក់ទំនងគតិយុត្តទេ។

# ទ្រឹស្តីទូទៅ( 3:បណ្តឹងទាមទារឲ្យបង្កើត ប្តូរ ឬ រំលត់ទំនាក់ទំនងគតិយុត្ត )

- ប្រុងប្រយ័ត្នអំពីភាពខុសគ្នារវាង ការបង្កើត ប្តូរ ឬ រំលត់ទំនាក់ទំនងគតិយុត្តនេះ ជាមួយនឹង សិទ្ធិបង្កើត ប្តូរ ឬ រំលត់ ដែលមានដូចជាសិទ្ធិរំលាយកិច្ចសន្យាដែលផ្អែកលើទ្រព្យសម្បត្តិទូទៅ ឬ សិទ្ធិលុបចោលនូវការបង្ហាញឆន្ទៈជាដើម។

  A បានចាញ់ប្រោក B បោកប្រាស់ ហើយបានលក់រូបគំនូរឲ្យទៅ B ប៉ុន្តែ Aបានដឹងខ្លួនថា បានចាញ់បោកB ដូច្នេះ A អាចធ្វើឲ្យកិច្ចសន្យាលក់ទិញនេះមោឃៈបាន តាមរយៈការបង្ហាញឆន្ទៈលុបចោលនូវកិច្ចសន្យា (ក្រមរដ្ឋប្បវេណីមាត្រា 347 កថាខណ្ឌទី1)។
  ក្នុងករណីនេះ មិនចាំបាច់ដាក់ពាក្យបណ្តឹងទាមទារឲ្យបង្កើត ប្តូរ ឬ រំលត់ទំនាក់ទំនងគតិយុត្ត ដើម្បីលុបចោល ឬ រំលាយកិច្ចសន្យាលក់ទិញទេ។

→ អញ្ចឹង បើភាគីចង់ឲ្យតុលាការប្រកាសអំពីការលុបចោល ឬ ការរំលាយកិច្ចសន្យាវិញ តើត្រូវធ្វើយ៉ាងណា?
→ ភាគីអាចធ្វើឡើងក្រៅផ្លូវតុលាការ ឬ តាមផ្លូវតុលាការដោយដាក់ពាក្យបណ្តឹងទាមទារឲ្យបញ្ជាក់អំពីនត្ថិភាពនៃទំនាក់ទំនងកិច្ចសន្យាដោយផ្អែកតាមការបង្ហាញឆន្ទៈលុបចោលជាដើម។

# ទ្រឹស្តីទូទៅ(3:បណ្តឹងទាមទារឲ្យបង្កើត ប្តូរ ឬ រំលត់ទំនាក់ទំនងគតិយុត្ត)

- សេចក្តីសម្រេចបញ្ចប់នៃបណ្តឹងទាមទារឲ្យបង្កើត ប្តូរ ឬ រំលត់ទំនាក់ទំនងគតិយុត្ត

"លែងលះដើមចោទជាមួយចុងចម្លើយ។"

"មិនអនុញ្ញាតឲ្យចុងចម្លើយធ្វើការអនុវត្តដោយបង្ខំផ្អែកតាមសាលក្រមនៃរឿងក្តីលេខ.....ឆ្នាំ..... របស់តុលាការ.....ចំពោះដើមចោទទេ។"

※បង្ហាញឲ្យច្បាស់លាស់អំពីទំនាក់ទំនងនៃសិទ្ធិដែលត្រូវបានបង្កើត ប្តូរ ឬ រំលត់ក្នុងសេចក្តីសម្រេចបញ្ចប់

※ជៀសវាងសំនួនដែលស្រដៀងនឹងសាលក្រមឲ្យផ្តល់តាវកាលិក ឬ សាលក្រមទាមទារឲ្យបញ្ជាក់ (ឧទាហរណ៍៖ បង្គាប់ឲ្យលែងលះ.....។" "ចុងចម្លើយមិនត្រូវអនុវត្តដោយបង្ខំ....." ជាដើម គឺ X ។)

# ទ្រឹស្តីលម្អិត: ករណីសិក្សា1 (ករណីទាមទារឲ្យចុះបញ្ជីផ្ទេរផ្អែកតាមកិច្ចសន្យា)

- ទំនាក់ទំនងអង្គហេតុ
  - នៅថ្ងៃទី1 ខែ12 ឆ្នាំ2017 អ្នកទិញ A បានចុះកិច្ចសន្យាទិញលក់ដី X ជាមួយអ្នកលក់ B ដោយបានធ្វើលិខិតយថាភូត និង បានបង់ប្រាក់ចំនួន1លានដុល្លារឲ្យទៅ B ។ ប៉ុន្តែ B បានអះអាងអំពីការលុបចោលកិច្ចសន្យាផ្អែកតាមមូលហេតុភាន់ច្រឡំ ហើយមិនព្រមសហការចុះបញ្ជីផ្ទេរនោះទេ។
  - A បានដាក់ពាក្យបណ្តឹងទាមទារឲ្យចុះបញ្ជីផ្ទេរកម្មសិទ្ធិផ្អែកតាមកិច្ចសន្យាលក់ទិញទៅកាន់ B។

# ទ្រឹស្តីលម្អិត ៖ករណីសិក្សា1
# （ករណីទាមទារឲ្យចុះបញ្ជីផ្ទេរដោយផ្អែកតាមកិច្ចសន្យា）

【សំនួរ1】
　សូមសរសេរសេចក្តីសម្រេចបញ្ចប់ ករណីដែលតុលាការបានទទួលស្គាល់នូវការអះអាងរបស់ A។

【សំនួរ2】
　ក្នុងករណីដែលគោលបំណងនៃការទាមទារក្នុងពាក្យបណ្តឹងរបស់ A សរសេរថា "សូមឲ្យតុលាការទទួលស្គាល់ថា ដី A ជាកម្មសិទ្ធិរបស់ X" ប៉ុន្តែ ក្រោយពេលមកនៅក្នុងនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ជាអាទិ៍ បែរជាបង្ហាញថា ជាការអះអាងនោះគឺជា ការទាមទារឲ្យចុះបញ្ជីផ្ទេរកម្មសិទ្ធិទៅវិញ តើគួរដោះស្រាយដោយរបៀបណា?

# ទ្រឹស្តីលម្អិត :ករណីសិក្សា1
# (ករណីទាមទារឲ្យចុះបញ្ជីផ្ទេរដោយផ្អែកតាមកិច្ចសន្យា)

【ចម្លើយ1】

"បង្គាប់ឲ្យចុងចម្លើយធ្វើនីតិវិធីចុះបញ្ជីផ្ទេរកម្មសិទ្ធិទាំងមូលនូវដីដែលសរសេរនៅក្នុងតារាងឧបសម្ព័ន្ធនៃបញ្ជីសារពើភ័ណ្ឌស្តីពីសិទ្ធិប្រត្យក្សឲ្យទៅដើមចោទ ដោយផ្អែកតាមមូលហេតុការលក់ទិញចុះថ្ងៃទី1 ខែ12 ឆ្នាំ2017។" ○

"កម្មសិទ្ធិករនៃដីដែលសរសេរក្នុងតារាងឧបសម្ព័ន្ធនៃបញ្ជីសារពើភ័ណ្ឌស្តីពីសិទ្ធិប្រត្យក្សគឺជា A។" ✕

"បង្គាប់ឲ្យមន្ត្រីចុះបញ្ជីធ្វើនីតិវិធីចុះបញ្ជីនូវដីដែលសរសេរក្នុងតារាងឧបសម្ព័ន្ធនៃបញ្ជីសារពើភ័ណ្ឌស្តីពីសិទ្ធិប្រត្យក្ស។" ✕

# ទ្រឹស្តីលម្អិត ：ករណីសិក្សា1
# (ករណីទាមទារឲ្យចុះបញ្ជីផ្ទេរដោយផ្អែកតាមកិច្ចសន្យា)

ពាក្យសុំចុះបញ្ជី ជាគោលការណ៍ត្រូវធ្វើពាក្យសុំរួមគ្នា (ប្រកាសអន្តរក្រសួងស្តីពី នីតិវិធីនៃការចុះបញ្ជីអំពីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណី ប្រការ 10)

ករណីលើកលែង ប្រសិនបើបុគ្គលមានកាតព្វកិច្ចចុះបញ្ជីមិនព្រមសហការ បុគ្គលដែលមានសិទ្ធិចុះបញ្ជីអាចដាក់ពាក្យសុំតែម្នាក់ឯងបាន "បើមានដីកាសម្រេច ឬ សាលក្រមស្ថាពរដែលជាលិខិតអនុវត្ត …បង្គាប់ឲ្យធ្វើនីតិវិធីចុះបញ្ជី " (មាត្រាដដែល កថាខណ្ឌទី២)

សាលក្រមស្ថាពរដែលជាលិខិតអនុវត្ត គឺជាអ្វី?
→សាលក្រមបង្គាប់ឲ្យផ្តល់តាវកាលិកដែលបានចូលជាស្ថាពរ (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា350)

# ទ្រឹស្តីលម្អិត :ករណីសិក្សា1
# (ករណីទាមទារឲ្យចុះបញ្ជីផ្ទេរដោយផ្អែកតាមកិច្ចសន្យា)

ក្រមនីតិវិធីរដ្ឋប្បវេណីមាត្រា529 (ការចាត់ទុកថាបានបង្ហាញឆន្ទៈ)

1 បើសាលក្រម សាលដីកា ឬ ដីកាសម្រេចបង្គាប់ឲ្យកូនបំណុលនៃការអនុវត្តបង្ហាញឆន្ទៈ ចូលជាស្ថាពរហើយ ឬ បើលិខិតអនុវត្តដោយផ្អែកលើការផ្សះផ្សា ឬ ការទទួលស្គាល់ដែលមានខ្លឹមសារថាកូនបំណុលនៃការអនុវត្តត្រូវបង្ហាញឆន្ទៈ ត្រូវចាត់ទុកថា កូនបំណុលនៃការអនុវត្តបានបង្ហាញឆន្ទៈ នៅពេលនៃការចូលជាស្ថាពរ ឬ ការបង្កើតអានុភាពនោះ ។ <សង្ខេប>

2 <សង្ខេប>

"សាលក្រម ឬ សាលដីកាដែលបង្គាប់ឲ្យត្រូវតែបង្ហាញឆន្ទៈ"= សាលក្រមបង្គាប់ឲ្យផ្តល់តាវកាលិក

# ទ្រឹស្តីលម្អិត : ករណីសិក្សា1
# ( ករណីទាមទារឲ្យចុះបញ្ជីផ្ទេរដោយផ្អែកតាមកិច្ចសន្យា )

■ ហេតុអ្វីបានជាការសរសេរថា "កម្មសិទ្ធិករនៃដីដែលសរសេរក្នុងតារាងឧបសម្ព័ន្ធនៃបញ្ជីសារពើភ័ណ្ឌស្តីពីសិទ្ធិប្រត្យក្ស គឺជា A" មិនត្រឹមត្រូវ ?

→ ការសរសេរដូចខាងលើនេះ មិនមែនការសរសេរនៅក្នុងជាសាលក្រមដែលបង្គាប់ឲ្យផ្តល់តាវកាលិកជាក់លាក់នោះទេ (សាលក្រមបង្គាប់ឲ្យផ្តល់តាវកាលិក) ហើយវាគឺ ជាការសរសេរនៅក្នុងសាលក្រមបញ្ជាក់ ។

→ <u>នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីមាត្រា350 កថាខណ្ឌទី2 មិនបានសរសេរអំពី សាលក្រមបញ្ជាក់ទេ ដូច្នេះ ហើយមិនអាចក្លាយជាលិខិតអនុវត្តនោះទេ ។</u>

→ ការដាក់ពាក្យសុំម្នាក់ឯងអាចធ្វើបាន លុះត្រាតែ "<u>មានដីកាសម្រេច ឬ សាលក្រមស្ថាពរដែលជាលិខិតអនុវត្ត</u>" បង្គាប់ឲ្យធ្វើនីតិវិធីចុះបញ្ជី (ប្រកាសអន្តរក្រសួងស្តីពី នីតិវិធីនៃការចុះបញ្ជីអំពីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណី ប្រការ 10 កថាខណ្ឌទី២)

→ ទោះបីជាភាគីបានទាមទារនូវការសហការដើម្បីដាក់ពាក្យសុំចុះបញ្ជីដោយផ្អែកតាមសាលក្រមបញ្ជាក់ក៏ដោយ បើភាគីម្ខាងទៀតមិនព្រមអនុវត្តដោយស្ម័គ្រចិត្តទេ ការដាក់ពាក្យសុំចុះបញ្ជីផ្ទេរកម្មសិទ្ធិតែម្នាក់ឯង មិនអាចធ្វើឡើងបានទេ។

# ទ្រឹស្តីលម្អិត ៖ករណីសិក្សា1 （ករណីទាមទារឲ្យចុះបញ្ជីផ្ទេរដោយផ្អែកតាមកិច្ចសន្យា）

- ចុះបើដាក់ពាក្យសុំចុះបញ្ជីផ្ទេរកម្មសិទ្ធិដោយបានភ្ជាប់សាលក្រមបញ្ជាក់ទៅជាមួយវិញ យ៉ាងម៉េចដែរ?

→ រដ្ឋបាលសុរិយោដីនឹងលើកចោលពាក្យសុំ។

→ ប៉ុន្តែ ក៏មានករណីដែលមេធាវី ឬ ចៅក្រម បានអះអាងថា ការមិនអនុវត្តនូវការចុះបញ្ជីដែលផ្អែកតាមសាលក្រមបញ្ជាក់ គឺជា គឺជាអំពើខុសច្បាប់ដែលបានបញ្ញត្តនៅក្នុងក្រមព្រហ្មទណ្ឌ មាត្រា 520 ប៉ុន្តែ ការយល់បែបនេះ គឺជាការយល់ច្រឡំដ៏ធំ។

→ <u>ត្រូវតែចងចាំថា ការដាក់ញស្សុំតែម្នាក់ឯងផ្អែកតាមសាលក្រមបញ្ជាក់ដែលបានធ្វើឡើងដោយភាគីឈ្នះក្តី គឺជាសកម្មភាពផ្ទុយទៅនឹង ក្រមនីតិវិធីរដ្ឋប្បវេណីមាត្រា350 ប្រកាសអន្តរក្រសួងស្តីពីនីតិវិធីនៃការចុះបញ្ជីអំពីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណី ប្រការ 10 កថាខណ្ឌទី២ ដែលផ្អែកតាម មាត្រា529នៃក្រមនីតវិធីរដ្ឋប្បវេណី។</u>

# ទ្រឹស្តីលម្អិត : ករណីសិក្សា1
# (ករណីទាមទារឲ្យចុះបញ្ជីផ្ទេរដោយផ្អែកតាមកិច្ចសន្យា)

- ហេតុអ្វីបានជាការសរសេរថា "បង្គាប់ឲ្យមន្ត្រីចុះបញ្ជីធ្វើនីតិវិធីចុះបញ្ជីនូវដីដែលមានសរសេរក្នុងតារាងឧបសម្ព័ន្ធនៃបញ្ជីឧបសម្ព័ន្ធស្តីពីសិទ្ធិប្រត្យក្ស។" មិនត្រឹមត្រូវ?

→បណ្តឹងទាមទារឲ្យចុះបញ្ជី គឺជាបណ្តឹងដែលទាមទារឲ្យបុគ្គលមានកាតព្វកិច្ចចុះបញ្ជីត្រូវតែបង្ហាញឆន្ទៈ ផ្អែកតាមរយៈការចូលជាស្ថាពរនៃសាលក្រម គេបានចាត់ទុកថា ភាគីបានធ្វើការបង្ហាញឆន្ទៈក្នុងសាលក្រមនោះ(ក្រមនីតិវិធីរដ្ឋប្បវេណីមាត្រា529)។

→មន្ត្រីចុះបញ្ជីមិនមែនជាបុគ្គលមានកាតព្វកិច្ចចុះបញ្ជីទេ ហេតុនេះ មិនអាចចាត់ទុកថាបានបង្ហាញឆន្ទៈនោះទេ។

# ទ្រឹស្តីលម្អិត ៖ករណីសិក្សា1
# (ករណីទាមទារឲ្យចុះបញ្ជីផ្ទេរដោយផ្អែកតាមកិច្ចសន្យា)

■ តើត្រូវភ្ជាប់ជាមួយការប្រកាសឲ្យអនុវត្តជាបណ្តោះអាសន្ន (ក្រមនីតិវិធីរដ្ឋប្បវេណីមាត្រា196) ដែរឬទេ?

1 ចំពោះសាលក្រមដែលសម្រេចអំពីការទាមទារសិទ្ធិលើទ្រព្យសម្បត្តិ បើយល់ឃើញថាចាំបាច់ តុលាការអាចប្រកាសថា សាលក្រមនោះអាចអនុវត្តជាបណ្តោះអាសន្នបាន ･･･<សង្ខេប>។

→ បណ្តឹងទាមទារឲ្យចុះបញ្ជី គេបានចាត់ទុកថាបានបង្ហាញឆន្ទៈ នៅពេលដែលសាលក្រមនោះបានចូលជាស្ថាពរ (ក្រមនីតិវិធីរដ្ឋប្បវេណីមាត្រា529)

→ បញ្ញត្តិនេះមិនបានទទួលស្គាល់ថា ការចាត់ទុកថាបានបង្ហាញឆន្ទៈអំពីការដាក់ពាក្យសុំចុះបញ្ជី "ជាបណ្តោះអាសន្ន" នៅមុនពេលសាលក្រមចូលជាស្ថាពរទេ។

→ មិនអាចភ្ជាប់នូវការប្រកាសឲ្យអនុវត្តជាបណ្តោះអាសន្នទេ។

# ទ្រឹស្តីលម្អិត ：ករណីសិក្សា1
# （ករណីទាមទារឲ្យចុះបញ្ជីផ្ទេរដោយផ្អែកតាមកិច្ចសន្យា）

【សំនួរ1】
សូមសរសេរសេចក្តីសម្រេចបញ្ចប់ អំពីករណីដែលតុលាការបានទទួលស្គាល់ការអះអាងរបស់ A។

【សំនួរ2】
ក្នុងករណីដែលគោលបំណងនៃការទាមទារក្នុងពាក្យបណ្តឹងរបស់ A សរសេរថា "សូមឲ្យតុលាការទទួលស្គាល់ថា ដី A ជាកម្មសិទ្ធិរបស់ X" ប៉ុន្តែ ក្រោយពេលមកនៅក្នុងនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ជាអាទិ៍ បែរជាបង្ហាញថា ជាការអះអាងនោះគឺជា ការទាមទារឲ្យចុះបញ្ជីផ្ទេរកម្មសិទ្ធិទៅវិញ តើគួរដោះស្រាយដោយរបៀបណា?

# ប្រធានបទ ៖ ករណីសិក្សា1 (ករណីទាមទារឲ្យចុះបញ្ជីផ្ទេរដោយផ្អែកតាមកិច្ចសន្យា)

【ចម្លើយ2】

តុលាការអនុវត្តសិទ្ធិឲ្យបំភ្លឺ (ក្រមនីតិវិធីរដ្ឋប្បវេណីមាត្រា90) និងជំរុញឲ្យផ្លាស់ប្តូរកម្មវត្ថុនៃបណ្តឹង (ក្រមនីតិវិធីរដ្ឋប្បវេណីមាត្រា 84) ពីបណ្តឹងទាមទារឲ្យបញ្ជាក់កម្មសិទ្ធិទៅជាបណ្តឹងទាមទារឲ្យចុះបញ្ជីផ្ទេរកម្មសិទ្ធិវិញ។

# ទ្រឹស្ដីលម្អិត : ករណីសិក្សា2
# (ករណីបណ្ដឹងទាមទារឲ្យបញ្ជាក់អំពីមោឃភាពនៃមតកសាសន៍)

- ទំនាក់ទំនងនៃអង្គហេតុ
  - មតកជនA បានបង្កើតមតកសាសន៍ជាលិខិតឯកជនដែលបានសរសេរថា "ធ្វើអច្ច័យទាននូវអចលនវត្ថុដែលមាននៅក្នុងបញ្ជីសារពើភ័ណ្ឌដែលភ្ជាប់មកជាមួយនេះ ឲ្យទៅកូនស្រីច្បងB" ហើយបានយកមកទុកនៅនឹងមេធាវី។ A មិនមានទ្រព្យសម្បត្តិអ្វីផ្សេងទៀតក្រៅពីអចលនវត្ថុដែលមាននៅក្នុងបញ្ជីសារពើភ័ណ្ឌដែលភ្ជាប់មកជាមួយនេះទេ។ 1ឆ្នាំក្រោយមក A បានទទួលមរណភាព ។ សន្តតិជនរបស់គាត់មានតែកូនចំនួន3នាក់តែប៉ុណ្ណោះ (កូនស្រីច្បងB កូនប្រុសច្បងC កូនប្រុសបន្ទាប់D)។

  - Cបានគិតថា មតកសាសន៍ខាងលើនេះ គឺជាមតកសាសន៍ដែល B បានផ្តួចផ្តើមឲ្យAសរសេរឡើង ដូច្នេះហើយ ជាមតកសាន៍ដែលត្រូវមោឃៈ។ ហើយ គាត់បានឃើញថា កាលពីឆ្នាំមុន A ស្ថិតក្នុងស្ថានភាពជម្ងឺចាស់ជរាដែលមានការភ្លេចភ្លាំង ដូច្នេះហើយ បានគិតថា A គ្មានសមត្ថភាពយល់ដឹងគ្រប់គ្រាន់នៅពេលដែលបង្កើតលិខិតមតកសាសន៍នោះទេ ។

  - C បានដាក់ពាក្យបណ្ដឹងទាមទារឲ្យបញ្ជាក់អំពីមោឃភាពនៃមតកសាសន៍ ទៅកាន់B ។ B បានអះអាងថា បណ្ដឹងនោះគ្មានផលប្រយោជន៍ដែលត្រូវធ្វើការបញ្ជាក់ទេ ដោយសារតែ ការបង្កើតមតកសាសន៍ គឺជាសកម្មភាពកាលពីអតីតកាល ហើយបានទាមទារឲ្យតុលាការលើកចោលពាក្យបណ្ដឹងនោះ។

# ទ្រឹស្តីលម្អិត：ករណីសិក្សា2
## （ករណីបណ្តឹងទាមទារឲ្យបញ្ជាក់អំពីមោឃភាពនៃមតកសាសន៍）

【សំណួរ1】
តើតុលាការគួរតែសម្រេចសេចក្តីបែបណា?

【សំណួរ2】
ឧទាហរណ៍ថា តុលាការបានសម្រេចថាបណ្តឹងនៅក្នុងរឿងក្តីនេះមានភាពត្រឹមត្រូវ ដោយបានចេញសាលក្រមច្រានចោលការទាមទារ ហើយសាលក្រមនេះបានចូលជាស្ថាពរ តើ D អាចដាក់ពាក្យបណ្តឹងទាមទារឲ្យបញ្ជាក់អំពីមោឃភាពនៃមតកសាសន៍នៃរឿងក្តីនេះម្តងទៀតបានដែរឬទេ?

# ទ្រឹស្តីលម្អិត៖ ករណីសិក្សា2 (ករណីបណ្តឹងទាមទារឲ្យបញ្ជាក់អំពីមោឃភាពនៃមតកសាសន៍)

■រំលឹកឡើងវិញអំពីទ្រឹស្តីទូទៅ៖

②ភាពត្រឹមត្រូវនៃកម្មវត្ថុនៃការទាមទារឲ្យបញ្ជាក់

ជាគោលការណ៍ កម្មវត្ថុនៃការទាមទារឲ្យបញ្ជាក់ គឺជាទំនាក់ទំនងនៃសិទ្ធិ ឬ ឋានៈតាមផ្លូវច្បាប់នាពេលបច្ចុប្បន្ន។

i បើសិនជាបញ្ជាក់អំពីទំនាក់ទំនងនៃសិទ្ធិ ឬ ឋានៈតាមផ្លូវច្បាប់ក្នុងពេលអតីតកាលក៏ដោយ ក៏ភាគច្រើនសិទ្ធិ ឬ ឋានៈនោះនៅក្នុងពេលបច្ចុប្បន្នមានការផ្លាស់ប្តូរ ហើយមិនមានប្រយោជន៍ក្នុងការដោះស្រាយវិវាទនាពេលបច្ចុប្បន្នទេ។

ii ដើម្បីធ្វើការបញ្ជាក់អំពីទំនាក់ទំនងនៃសិទ្ធិ និង ឋានៈតាមផ្លូវច្បាប់នាពេលអនាគត តុលាការត្រូវធ្វើការសេចក្តីសម្រេចដោយផ្អែកលើការព្យាករណ៍ទុក ហើយក្នុងករណីដែលលទ្ធផលខុសពីការព្យាករណ៍ទុក នឹងធ្វើឲ្យសាលក្រមនោះគ្មានន័យ ហើយមិនមានប្រយោជន៍អ្វីចំពោះការដោះស្រាយវិវាទទេ។

iii ទោះបីជាយកទំនាក់ទំនងនៃអង្គហេតុមកធ្វើជាកម្មវត្ថុនៃការបញ្ជាក់ក៏ដោយ ក៏ទំនាក់ទំនងនៃអង្គហេតុនេះមិនបានផ្សារភ្ជាប់ដោយផ្ទាល់ចំពោះការដោះស្រាយវិវាទតាមផ្លូវច្បាប់នាពេលបច្ចុប្បន្នដែរ។

# ទ្រឹស្តីលម្អិត៖ករណីសិក្សា2
# (ករណីបណ្តឹងទាមទារឲ្យបញ្ជាក់អំពីមោឃភាពនៃមតកសាសន៍)

【ចម្លើយ1】

→ ប្រសិនបើកម្មវត្ថុនៃការបញ្ជាក់ក្នុងសំណួរនេះ បានយកសុពលភាពនៃសកម្មភាពក្នុងការបង្កើតមតកសាសន៍របស់A ធ្វើជាកម្មវត្ថុ ដូច្នេះ កម្មវត្ថុនេះនឹងត្រូវទៅក្លាយជាកម្មវត្ថុនៃការទាមទារឲ្យបញ្ជាក់អំពីអានុភាពនៃសកម្មភាពគតិយុត្តនៅក្នុងអតីតកាល ហើយវាត្រូវនឹងចំណុច ② i ហើយប្រហែលជាមិនអាចកំណត់អំពីផលប្រយោជន៍នៃការបញ្ជាក់ផងក៏ថាបាន។

→ ប៉ុន្តែ ប្រសិនបើគិតថា មតកសាសន៍នោះត្រូវមោឃៈ ដូច្នេះ តាមផ្លូវច្បាប់ ឋានៈរបស់ C នឹងត្រូវមានចំណែកនៃចំណែកមត៌កដែលច្បាប់បានកំណត់ ។ ហើយប្រសិនបើគិតថា មតកាសាសន៍នោះ មានសុពលភាព ហើយ បានអនុវត្តនូវសិទ្ធិទាមទារឲ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងនោះ C នឹងមានសិទ្ធិលើចំណែកនៃភាគបម្រុង ។

# ទ្រឹស្តីលម្អិត：ករណីសិក្សា2
# （ករណីបណ្តឹងទាមទារឲ្យបញ្ជាក់អំពីមោឃភាពនៃមតកសាសន៍）

【ចម្លើយ1】

→ហេតុដូច្នេះហើយ ដើម្បីដោះស្រាយវិវាទទាក់ទងនឹងការបែងចែកមត៌កដែលកំពុងកើតឡើងនាពេលបច្ចុប្បន្នឲ្យបានទាំងស្រុង សុពលភាពនៃមតកសាសន៍នឹងមានអានុភាពស្ថាពរដែលមានលក្ខណៈសារធាតុ ហើយការចូលជាស្ថាពរនោះនឹងមានប្រយោជន៍។

→ប្រសិនបើគិតថា មតកសាសន៍មានសុពលភាព ទំនាក់ទំនងគតិយុត្តជាក់លាក់នាពេលបច្ចុប្បន្នដែលបានកើតចេញពីពេលដែលមតកសាសន៍នោះមានសុពលភាព នឹងត្រូវបានបកស្រាយថា គឺជាការទាមទារឲ្យបញ្ជាក់នត្ថិភាពនៃមតកសាសន៍ ហើយបណ្តឹងទាមទារឲ្យបញ្ជាក់អំពីមោឃភាពនៃមតកសាសន៍ក្នុងរឿងក្តីនេះនឹងមានសុពលភាព។

# ទ្រឹស្តីលម្អិត៖ ករណីសិក្សា2
## (ករណីបណ្តឹងទាមទារឲ្យបញ្ជាក់អំពីមោឃភាពនៃមតកសាសន៍)

【សំណួរ1】

តើតុលាការគួរតែសម្រេចសេចក្តីបែបណា?

【សំណួរ2】

ឧទាហរណ៍ថា តុលាការបានសម្រេចថាបណ្តឹងនៅក្នុងរឿងក្តីនេះមានភាពត្រឹមត្រូវ ដោយបានចេញសាលក្រមច្រានចោលការទាមទារ ហើយសាលក្រមនេះបានចូលជាស្ថាពរ តើ D អាចដាក់ពាក្យបណ្តឹងទាមទារឲ្យបញ្ជាក់អំពីមោឃភាពនៃមតកសាសន៍នៃរឿងក្តីនេះម្តងទៀតបានដែរឬទេ?

# ទ្រឹស្តីលម្អិត៖ករណីសិក្សា2
# （ករណីបណ្តឹងទាមទារឲ្យបញ្ជាក់អំពីមោឃភាពនៃមតកសាសន៍）

【ចម្លើយ2】

ក្នុងករណីដែលកម្មវត្ថុនៃការបញ្ជាក់ក្នុងបណ្តឹងទាមទារឲ្យបញ្ជាក់អំពីមោឃភាពនៃមតកសាសន៍ គឺ ជាការអះអាងអនត្ថិភាពទាំងស្រុង ឬ មួយផ្នែកនៃសិទ្ធិលើមត៌ក ហើយគេបានគិតថា មិនចាំបាច់យកសន្តតិជនទាំងអស់មកធ្វើជាភាគីទេនោះ C អាចដាក់ពាក្យបណ្តឹងទាមទារឲ្យបញ្ជាក់អំពីមោឃភាពនៃមតកសាសន៍តែម្នាក់ឯងបាន។ ហើយឧទាហរណ៍ថា សាលក្រមច្រានចោលការទាមទារនោះបានចូលជាស្ថាពរក៏ដោយ ក៏ D អាចដាក់ពាក្យបណ្តឹងទាមទារឲ្យបញ្ជាក់អំពីមោឃភាពនៃមតកសាសន៍ចំពោះមតកសាសន៍ដដែលនេះបានម្តងទៀតផងដែរ។

ចំពោះករណីនេះ គេគិតថា ក៏អាចធ្វើជាសហបណ្តឹងចាំបាច់ចំពោះបណ្តឹងទាមទារឲ្យបញ្ជាក់អំពីមោឃភាពនៃមតកសាសន៍បានដែរ ប្រសិនបើគូភាគីផ្តោតសំខាន់ទៅលើតួនាទីនៃការដោះស្រាយ និងការការពារវិវាទក្នុងបណ្តឹងទាមទារឲ្យបញ្ជាក់។

# សូមអរគុណ